# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០២.កយ.សណន-២០០៥

# សេចក្តីណែនាំរួម
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល

**ជម្រាបមក**

លោកប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង

លោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងអមតុលាការខេត្ត-ក្រុង

**កម្មវត្ថុ:** សេចក្តីណែនាំអំពីការអនុវត្តមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

កន្លងមកក្រសួងយុត្តិធម៌ និងតុលាការកំពូលបានពិនិត្យឃើញថា ការអនុវត្តមាត្រា ៤៦ ស្តីពីអំពើរំលោភលើសេចក្តីទុកចិត្ត នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ មិនទាន់បានឯកភាពគ្នានៅឡើយ នៅតាមតុលាការទូទាំងប្រទេស ម្យ៉ាងវិញទៀតចំពោះការបែងចែកវិវាទរដ្ឋប្បវេណី ដែលជាការមិនបំពេញករណីយកិច្ចកើតចេញពីកិច្ចសន្យា និងអំពើដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្តកំពុងស្ថិតនៅជា បញ្ហាដែលទាមទារឱ្យមានការដោះស្រាយផងដែរ ។

ការរំលោភសេចក្តីទុកចិត្ត គឺជាអំពើគេបន្លំ ឬបំបាត់ រំលោភកាន់កាប់មួយចំណែក ឬទាំងអស់នូវទ្រព្យសម្បត្តិអ្នកដទៃ ដែលគេបានប្រគល់អោយខ្លួនអាស្រ័យដោយការជឿទុកចិត្តរបស់ម្ចាស់ទ្រព្យ ឬអ្នកកាន់កាប់ទ្រព្យដែលសង្ឃឹមថា ទទួលបានមកវិញនូវទ្រព្យសម្បត្តិ ឬលទ្ធផលនៃការងារណាមួយពីអ្នកទទួលនូវទ្រព្យទាំងនោះ ។

ដើម្បីជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ និងការវិនិច្ឆ័យរឿង និងការបែងចែករវាងវិវាទ រដ្ឋប្បវេណី និងបទល្មើសរំលោភលើសេចក្តីទុកចិត្ត ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមធ្វើការណែនាំដល់តុលាការ និងអយ្យការខេត្ត-ក្រុង យកចិត្តទុកដាក់ពិចារណាលើសញ្ញាណគតិយុត្ត ដែលបានបញ្ញត្តិក្នុងមាត ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដូចរៀបរាប់ខាងក្រោម ។

**ធាតុផ្សំនៃបទល្មើសរំលោភលើសេចក្តីទុកចិត្តមាន ៖**

១-មានច្បាប់ចែង ឧទាហរណ៍ មាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

២-ជនល្មើសមានចេតនាទុច្ចរិត គៃបន្លំ ឬបំបាត់ ទ្រព្យដែលខ្លួនបានទទួល ពោលគឺការមិនបានប្រគល់ ឬបង្ហាញនូវទ្រព្យ ឬលទ្ធផលនៃការងារកើតឡើងដោយឆន្ទៈមិនប្រគល់ពិតប្រាកដ ដែលពុំមែនកើតឡើងដោយឧបសគ្គសត្យានុម័តនោះឡើយ ហើយត្រូវមានអំពើគៃបន្លំ ឬបំបាត់ទ្រព្យសម្បត្តិប្រព្រឹត្តដោយអ្នកទទួលបាននូវទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ដែលស្តែងឡើងក្រោមរូបភាពជាការមិនប្រគល់ ប្រគល់ តែបានបន្លំបរិមាណ ឬគុណភាពនៃទ្រព្យសម្បត្តិទាំងនោះ ។

៣-សម្ភារៈ ឬមុខសញ្ញា នៃបទរំលោភលើសេចក្តីទុកចិត្តរួមមាន ៖

ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ គ្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រកាសអោយដកខ្លួនក្នុងលក្ខណៈជាការជួល ការតម្កល់ទុក ជាអាណត្តិ ជាការអោយខ្ចី ប្រើ ឬ ដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសម្រាប់ប្រើប្រាស់ ឬ ជាមុខការមានកំណត់

ដែលម្ចាស់ទ្រព្យបានផ្ទុកផ្ដាក់ទ្រព្យរបស់ខ្លួនអោយទៅភាគីម្ខាង ហើយភាគីម្ខាងបាន ទទួលទ្រព្យនេះដោយស្របច្បាប់ តាមរយៈកិច្ចសន្យាប្រាំមួយ ប្រភេទគឺៈ កិច្ចសន្យាជួល កិច្ចសន្យាផ្ញើទុក កិច្ចសន្យាបញ្ចាំ កិច្ចសន្យាអោយខ្ចីប្រើ កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងាររវាងកម្មករ និងនិយោជិត ឬ មិនមែនរវាងនិយោជក និងកម្មករ និយោជិត ។

៤-មានការអន្តរាយ ពោលគឺខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ ដែលបានប្រគល់នូវ ទ្រព្យទាំងនោះ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមរំលឹក និងសូមឱ្យលោកចៅក្រម ពិចារណាឱ្យបានល្អិតល្អន់ចំពោះការមិនបានបំពេញករណីយកិច្ច ដែលកើតចេញពីកិច្ចសន្យារដ្ឋប្បវេណីផ្សេងទៀត ក្រៅពីប្រភេទ កិច្ចសន្យាទាំង៦ ដែលបានលើកឡើងខាងលើ ដូចជាកិច្ចសន្យាលក់-ទិញ កិច្ចសន្យាខ្ចីបរិភោគ( ដូចជាកិច្ចសន្យាខ្ចីប្រាក់ ) កិច្ចសន្យាឱ្យឬប្រទានកម្ម ដែលភ្ជាប់ករណីយកិច្ច .....ទោះបីដោយមូលហេតុណាក៏ដោយដែលអ្នកទទួលបាននូវទ្រព្យ មិនបានបំពេញករណីយកិច្ចប្រគល់ឱ្យទៅអ្នកប្រគល់វិញ នូវទ្រព្យនោះមិនមែនជាអំពើគៃបន្លំ ឬបំបាត់ ដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្ដីទុកចិត្តនោះឡើយ ។

ការធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិតាមរយៈអំពើណាមួយដែលមិនរួមផ្សំជាបទល្មើស រំលោភលើសេចក្ដីទុកចិត្ត អាចជាបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអំពើនោះត្រូវបានចែងក្នុងច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងមានវិធានការតាមផ្លូវច្បាប់ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូលសង្ឃឹមថា អស់លោកចៅក្រម នឹងយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តឱ្យបានត្រឹមត្រូវនូវបញ្ញត្តិមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដើម្បីការពារសិទ្ធិរបស់ពលរដ្ឋជួយរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបង្កើនការជឿជាក់របស់ពលរដ្ឋ និងអ្នកវិនិយោគលើប្រពន្ធ័តុលាការ និងច្បាប់របស់កម្ពុជា។

ភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៥

**ប្រធានតុលាការកំពូល** **រដ្ឋមន្ត្រី**

**ឌិត មុន្ទី** **អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និង មហាអយ្យការ